# អនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី២១/០៦/១៩៩៦
# ស្តីពី
# ថ្លៃអាករលើឯកសារធ្វើដំណើរ លិខិតបើកផ្លូវ ប័ណ្ណស្នាក់នៅបណ្តោះអាសន្ន និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ សម្រាប់ជនបរទេសអន្តោប្រវេសន្តន៍

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកត-០១៩៦-០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ច្បាប់ស្តីពីអន្តោប្រវេសន្តដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៥ ន/ស ៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា ១.-** អាករលើលិខិតធ្វើដំណើរត្រូវកំណត់ដូចខាងក្រោម ៖

ក- ឯកសារធ្វើដំណើរ ចំនួនបីសែនរៀល (៣០០.០០០៛០០) ។

ខ- លិខិតបើកផ្លូវ ចំនួនប្រាំម៉ឺនរៀល (៥០.០០០៛០០) ។

**មាត្រា ២.-** អាករលើការពន្យារលិខិតធ្វើដំណើរត្រូវកំណត់ដូចខាងក្រោម ៖

ក- ការពន្យារពេលឯកសារធ្វើដំណើរ ចំនួនប្រាំម៉ឺនរៀល (៥០.០០០៛០០) ។

ខ- ការពន្យារពេលលិខិតបើកផ្លូវ ចំនួនបីម៉ឺនប្រាំពីរពាន់ប្រាំរយរៀល (៣៧.៥០០៛០០)។

**មាត្រា ៣.-** កុមារទាំងពីរភេទមានអាយុ ១២ឆ្នាំ ចុះដែលរួមដំណើរជាមួយឪពុក ម្តាយ ឬអាណាព្យាបាល ត្រូវបានរួចអាករ ។

**មាត្រា ៤.**- អាករលើប័ណ្ណស្នាក់នៅត្រូវកំណត់ដូចខាងក្រោម ៖

ក- ប័ណ្ណស្នាន់នៅបណ្តោះអាសន្ន (មានសុពលភាព ១ឆ្នាំ ជាអតិបរិមា) ចំនួនពីរសែនប្រាំម៉ឺនរៀល (២៥០.០០០៛០០) ។

ខ- ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ (មានសុពលភាព ២ឆ្នាំ) ចំនួនប្រាំសែនរៀល (៥០០.០០០៛០០) ។

គ- ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ទុតិយតា ចំនួនប្រាំសែនរៀល (៥០០.០០០៛០០) ។

**មាត្រា៥.**-ថ្លៃអាករលើការពន្យារពេលប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ត្រូវកំណត់ចំនួនប្រាំសែនរៀល (៥០០.០០០៛០០) ។

**មាត្រា ៦.**- ថ្លៃអាករគ្រប់ប្រភេទខាងលើនេះ ត្រូវបង់ចូលថវិកាជាតិ ។ បែបបទនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ។

**មាត្រា ៧.**- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨.**- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ មុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ មិថុនា ឆ្នាំ ១៩៩៦

នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ | ហ៊ុន សែន

បានបង្គំទូលថ្វាយ និងជំរាបជូន

សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង | យូ ហុកគ្រី